**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
គណៈកម្មការសម្រាប់សិក្សា និងរៀបចំសាងសង់វិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា
លេខ : ០១ស.ជ.៣

# សេចក្តីជូនដំណឹង
# ស្តីពី
# ការចូលទស្សនកិច្ចវិមានឈ្នះ ឈ្នះ

គណៈកម្មការសម្រាប់សិក្សា និងសាងសង់វិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ហៅកាត់ថា "**គណៈកម្មការសាងសង់វិមានឈ្នះ ឈ្នះ**" មានកិត្តិយសសូមជម្រាបជូន ក្រសួង ស្ថាប័ន ភ្ញៀវទេសចរណ៍ និងសាធារណជនជាតិ អន្តរជាតិទាំងអស់ មេត្តាជ្រាបថា ឈរលើស្មារតីគោរពស្រឡាញ់ និងបញ្ជាក់ពីការគាំទ្រ ការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានកសាងតឹកតាងប្រវត្តិសាស្ត្រជាតិពិត ដែលមិនធ្លាប់មានជាប្រវត្តិសាស្ត្រនៅលើទឹកដីកម្ពុជា ទើបនៅក្នុងរយៈពេល០៥សប្តាហ៍ចុងក្រោយនេះ បន្ទាប់ពីការសម្ពោធវិមាន ឈ្នះ ឈ្នះ និងអបអរសាទរខួបលើកទី២០នៃទិវានយោបាយ ឈ្នះ ឈ្នះ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨កន្លងមក បានធ្វើឲ្យវិមាន ឈ្នះ ឈ្នះ ទទួលបានការទាក់ទាញ និងយកចិត្តទុកដាក់ពីសំណាក់សាធារណជនជាតិ អន្តរជាតិ ប្រាថ្នាចូលទស្សនាយល់ដឹង និងឈ្វេងយល់ជាប់ប្រចាំជារៀងរាល់ថ្ងៃទាំងព្រឹក ល្ងាច និងយប់ ។

បច្ចុប្បន្នក្រុមការងារបានបន្តនិរន្តរភាពក្នុងដំណាក់កាលអន្តរកាលរបស់ខ្លួន ដោយទទួលភារកិច្ចដ៏ធំធេងឈរលើស្មារតីទទួលខុសត្រូវ និងម្ចាស់ការខ្ពស់តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានគណៈកម្មការសាងសង់វិមាន ឈ្នះ ឈ្នះ** បានប្រគល់ជូន ។

ដោយសារសមាជិកក្រុមការងារទទួលបន្ទុកវិមាន ឈ្នះ ឈ្នះ សមត្ថភាពនៅមានកម្រិត ក្នុងការផ្តល់សេវា និងបច្ចេកទេសមិនទាន់ឆ្លើយតបបានទៅនឹងទីតាំងដែលទើបចាប់ផ្តើមកសាងនេះ ដូចជា បរិវេណតូច ការធានាគ្រប់គ្រង ផ្តល់សេវាបច្ចេកទេស អគ្គិសនី និងរបៀបរបបសណ្តាប់ធ្នាប់ចេញ ចូលនៅមានកម្រិត ទៅតាមទំហំសេចក្តីត្រូវការរបស់ទស្សនិកជនជាតិ អន្តរជាតិ ។ ដូចនេះ គណៈកម្មការសាងសង់វិមាន ឈ្នះ ឈ្នះ សូមជូនដំណឹងដូចតទៅ ៖

- **សារមន្ទីរមត្តុទ្ទេសក៍តេជោសែន** នឹងរៀបចំបើកឱ្យចូលទស្សនាជារៀងរាល់ថ្ងៃពុធ សុក្រ សៅរ៍ និងអាទិត្យ ចាប់ពី ***ម៉ោង១៤:០០នាទី ដល់ម៉ោង១៧:០០នាទី***
- ចំពោះការបើកចូលទស្សនាក្រៅពីពេលវេលាកំណត់ខាងលើ គណៈកម្មការសាងសង់វិមាន ឈ្នះ ឈ្នះ អនុញ្ញាតជូនតែមន្ត្រីរាជការ ក្រសួង ស្ថាប័ន និងក្រុមកម្មសិក្សានីមួយៗ ដែលបានស្នើសុំជាផ្លូវការ
- ចំពោះតំបន់សុខដុមនីយកម្ម តំបន់សួនតេជោសន្តិភាព រូបចម្លាក់ និងបរិវេណជុំវិញ អនុញ្ញាតជូនចូលទស្សនាជាធម្មតា ។

ដោយសារវិមាន ឈ្នះ ឈ្នះ នឹងក្លាយជាសំណង់រយឆ្នាំសម្រាប់អនាគត ដូចនេះ ទើបតែចាប់ផ្តើមដាក់ជូនទស្សនាជំហានដំបូងដ៏ខ្លីប៉ុណ្ណោះ ទទួលបានការចូលរួមដ៏សុទ្ធចិត្តពីសាធារណៈជនគ្រប់ស្រទាប់ រួមទាំងអ្នកសិក្សាស្រាវជ្រាវនានា ដំណើរការដ៏វែងឆ្ងាយដែលត្រូវបន្ត ដូចនេះ គណៈកម្មការនឹងផ្តល់ដំណឹងជូនជាក់ស្តែងតាមជំហាន

និងតាមដំណាក់កាលនីមួយៗថែមទៀត ។ ក្រុមការងារបានរៀបចំទីតាំងផ្តល់ព័ត៌មានមួយនៅខាងមុខជាបណ្តោះ-អាសន្ន ដើម្បីចែករំលែកព័ត៌មាន ព្រមទាំងការយល់ដឹងអំពីការតាំងពិព័រណ៍ និងការបញ្ចាំងខ្សែវីដេអូបឋម ដើម្បីជាការសិក្សាស្វែងយល់ជាមុន មុននឹងដំណើរទស្សនកិច្ចនៅជុំវិញវិមាន ឈ្នះ ឈ្នះ ។

ដើម្បីឲ្យការចូលទស្សនានៅតំបន់វិមាន ឈ្នះ ឈ្នះ ងាយយល់ដឹងបានទូលំទូលាយ ឆ្លើយតបទៅនឹងរូបចម្លាក់ ទម្រង់សំណង់ និងរឿងរ៉ាវ នៅក្នុងសារមន្ទីរ ក្រុមការងារសំណូមពរដល់គណៈប្រតិភូទស្សនកិច្ច និងសាធារណជនជាតិ អន្តរជាតិទាំងអស់ មុននឹងអញ្ជើញមកទស្សនានៅវិមាន ឈ្នះ ឈ្នះ គប្បីទស្សនាខ្សែវីដេអូដែលមានចំណងជើងថា **"មាតាសង្គ្រោះជាតិកម្ពុជា"** ជាប្រវត្តិជាក់ស្តែងក្នុងការយកជីវិតធ្វើជាដើមទុនរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ទស្សនាវីដេអូខ្លីៗស្តីពី **"ដំណើរការអនុវត្តនយោបាយឈ្នះ ឈ្នះ" "សំណង់វិមាន ឈ្នះ ឈ្នះ"** និងអត្ថន័យទាក់ទងទៅនឹងប្រវត្តិសាស្ត្រនៃការកសាងដែលមានអត្ថន័យទាក់ទងជាមួយនឹងខ្លឹមសារ ដែលគណៈកម្មការសាងសង់វិមាន ឈ្នះ ឈ្នះ ធ្លាប់បានផ្តល់ជូនតាមរយៈបទសម្ភាសន៍ជាមួយប្រព័ន្ធទូរទស្សន៍ សៀវភៅ និងឯកសារផ្សេងៗ ដែលបានចែកជូនកន្លងមក ។ នាពេលខាងមុខ ដើម្បីផ្តល់ជូនសាធារណៈជនជ្រាប អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាតិ កាន់តែប្រសើរឡើងថែមទៀត ក្រុមការងារនឹងរៀបចំសារមន្ទីរបន្ថែមនៅជាន់ផ្ទាល់ដី តាមលទ្ធភាព និងពេលវេលាជាក់ស្តែង ។

ជាការចូលរួមចំណែកទាំងអស់គ្នា ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់ បរិស្ថាន និងសោភ័ណ្ឌភាពស្អាត ប្រកបដោយអនាម័យ គណៈកម្មការសាងសង់វិមាន ឈ្នះ ឈ្នះ សំណូមពរយ៉ាងទទូចចំពោះសាធារណជនជាតិ អន្តរជាតិទាំងអស់ ដែលមានគោលបំណងអញ្ជើញទស្សនាវិមាន ឈ្នះ ឈ្នះ សូមមេត្តាយកចិត្តទុកដាក់ចូលរួមអនុវត្តប្រការមួយចំនួន ដូចតទៅ ៖

១.ចូលរួមទស្សនាដោយអធិដ្ឋាននូវបាវចនាទាំង៣នៃវិមាន ឈ្នះ ឈ្នះ គឺភាពកតញ្ញូ សុខដុម និងការចូលរួមចំណែកទាំងអស់គ្នា ដើម្បីសិក្សាឈ្វេងយល់ ឲ្យបានស៊ីជម្រៅនូវអត្ថន័យនយោបាយ ឈ្នះ ឈ្នះ ដើម្បីបន្តការអភិវឌ្ឍឲ្យក្លាយទៅជាទីឋានសក្ការៈ សម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រជាតិ សម្រាប់មនុស្សជំនាន់ក្រោយ និងតទៅមុខ ។

២.ក្នុងពេលដំណើរការ ទស្សនានៅបរិវេណវិមាន ឈ្នះ ឈ្នះ សូមចូលរួមធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ តាមសេចក្តីណែនាំរបស់ក្រុមមគ្គុទ្ទេសក៍ប្រចាំការ ។

៣.សូមជួយថែរក្សាការពារក្បាច់ចម្លាក់ រចនាបថស្ថាបត្យកម្មនៃសំណង់ និងសោភ័ណភាព ដើម្បីធានារក្សាបានអនាម័យខ្ពស់ មិនមានការហូបចុក ឬយកសម្ភារៈ សំរាមដែលធ្វើឲ្យបាត់សោភណ្ឌភាព ប៉ះពាល់ដល់សំណង់វិមាន ឈ្នះ ឈ្នះ និងសំណង់អម ឬអាងទឹក ដែលនាំឲ្យខូចខាតលក្ខណៈបច្ចេកទេសដើមនៃសំណង់ ដូចជា ការប៉ះពាល់រូបចម្លាក់ ដើមឈើ ដែលជាសម្បត្តិសាធារណៈ ដើម្បីរក្សាទុកតកូនតចៅជំនាន់ក្រោយ ។

គណៈកម្មការសាងសង់វិមាន ឈ្នះ ឈ្នះ សូមថ្លែងអំណរគុណទុកជាមុន និងមានជំនឿយ៉ាងមុតមាំថា សាធារណជនជាតិ អន្តរជាតិ នឹងចូលរួមចំណែកសហការរួមគ្នា ដើម្បីថែរក្សាកសាងតឹកតាងប្រវត្តិសាស្ត្រជាតិ ដែលពុំធ្លាប់មាននេះ ជារៀងរហូត ។

ក្រុមការងារសូមទទួលយករាល់គំនិតយោបល់ ដែលមានបំណងជួយស្ថាបនា តាមរយៈគេហទំព័រFacebook វិមានឈ្នះ ឈ្នះ Win-Win Memorial ឬតាមរយៈការផ្តល់មតិយោបល់ដោយផ្ទាល់ ឬជាមួយសមាជិកក្រុមការងារប្រចាំការ ។

ថ្ងៃអង្គារ ១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩

**ជ. គណៈកម្មការសាងសង់វិមានឈ្នះ ឈ្នះ**

**សមាជិកអចិន្ត្រៃយ៍ និងជាប្រធានក្រុមការងារ**

នាយឧត្តមសេនីយ៍. **ណឹម_សុវត្ថិ**